ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ៥៧២...ប្រក.

ភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការបង្កើត និងដាក់ឱ្យប្រើប្រាស់ឯកសារបំរើឱ្យការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet. Com. Kh

- បានឃើញប្រកាសលេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្មខេត្ត ក្រុង និង តួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

# សម្រេច

**ប្រការ ១ .-**

ឯកសារដូចមានរាយឈ្មោះខាងក្រោមនេះ ត្រូវបានបង្កើតឡើងដើម្បីបំរើឱ្យការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ :

- ពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ( ឧបសម្ព័ន្ធទី៤ )
- ពាក្យស្នើសុំចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន ( ឧបសម្ព័ន្ធទី៥ )
- សៀវភៅទទួលពាក្យ ( ឧបសម្ព័ន្ធទី៦ )
- បង្កាន់ដៃទទួលពាក្យ ( ឧបសម្ព័ន្ធទី៧ )
- សេចក្តីជូនដំណឹង ( ឧបសម្ព័ន្ធទី៨)
- ទម្រង់បែបបទប្រមូលទិន្នន័យចំណែកឯកជននៃអគារសហកម្មសិទ្ធិ ( ឧបសម្ព័ន្ធទី៩ )
- បញ្ជីឈ្មោះម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ( ឧបសម្ព័ន្ធទី១០)
- បញ្ជីឈ្មោះម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិ ( ឧបសម្ព័ន្ធទី១១)
- សេចក្តីជូនដំណឹង ស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យចំណែកឯកជននៃអគារសហកម្មសិទ្ធិ ( ឧបសម្ព័ន្ធទី១២)
- សៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ( ឧបសម្ព័ន្ធទី១៣ )
- សៀវភៅគោលបញ្ជីចុះសិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន ( ឧបសម្ព័ន្ធទី១៤ )
- វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន ( ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៩ )
- វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន ( ឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យលេខ ១២៦ អនក្រ.ប ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩)

**ប្រការ ២ .-**

ពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ឬពាក្យស្នើសុំចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិ គឺជាលិខិតរដ្ឋបាលដែលសាមីអ្នកកាន់កាប់ចំណែកឯកជន ឬអ្នកជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវបំពេញទៅតាមគំរូដែលរដ្ឋបាលសុរិយោដីបានរៀបចំ រួចដាក់ជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ដើម្បីចាត់ចែងទៅតាមនីតិវិធីជាធរមាន ។ នៅពេលទទួលពាក្យស្នើសុំ រដ្ឋបាលសុរិយោដីត្រូវកត់ចូលក្នុងសៀវភៅមួយមានឈ្មោះថា " សៀវភៅទទួលពាក្យ " រួចចេញបង្កាន់ដៃជូនសាមីអ្នកស្នើសុំ ជាភស្តុតាងបញ្ជាក់អំពីការដាក់ពាក្យនេះ ។

ប្រការ ៣ .-

ទម្រង់បែបបទប្រមូលទិន្នន័យចំណែកឯកជន គឺជាឯកសារកត់ត្រាព័ត៌មានទាក់ទងនឹងស្ថានភាពនៃចំណែកឯកជន នីមួយៗ អត្តសញ្ញាណ និងស្ថានភាពស៊ីវិលនៃបុគ្គលជាម្ចាស់សិទ្ធិនៃចំណែកឯកជន ព្រមទាំងប្រភពដែលទទួលបាន និងប្រភេទនៃទ្រព្យនោះ ។

ប្រការ ៤ .-

សៀវភៅគោលបញ្ជីចំណែកឯកជន គឺជាឯកសារគោលដែលកត់ត្រាទិន្នន័យសំខាន់ៗ ដកស្រង់ចេញពីទម្រង់បែបបទប្រមូលទិន្នន័យចំណែកឯកជន ។

ខ្លឹមសារដែលត្រូវកត់ត្រាក្នុងសៀវភៅគោលបញ្ជីចំណែកឯកជន មានដូចខាងក្រោម :

១. លេខរៀងក្នុងសៀវភៅ

២. អត្តសញ្ញាណនៃចំណែកឯកជន ( លេខចំណែកឯកជន , លេខជង់(BLOCK) , ជាន់ទី , ប្រភេទនៃសំណង់ ដោយយោងតាមប្លង់ស្ថាបត្យកម្ម )

៣. អត្រានុកូលដ្ឋានម្ចាស់សិទ្ធិ

៤. ការផ្លាស់ប្តូរ

៥. សេចក្តីផ្សេងៗ ។

ប្រការ ៥ .-

សៀវភៅគោលបញ្ជីចុះសិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន គឺជាឯកសារគោលដែលកត់ត្រាទិន្នន័យសំខាន់ៗ ដកស្រង់ចេញពីទម្រង់បែបបទប្រមូលទិន្នន័យចំណែកឯកជននៃអគារសហកម្មសិទ្ធិ ជួលអចិន្ត្រៃយ៍ ។

ប្រការ ៦ .-

សៀវភៅគោលបញ្ជីចំណែកឯកជន ឬសៀវភៅគោលបញ្ជីចុះសិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន នៃអគារសហកម្មសិទ្ធិ ត្រូវបានរៀបចំជាពីរ (០២) ច្បាប់ដូចគ្នា ទាំងទម្រង់និងខ្លឹមសារ ក្នុងនោះ មួយច្បាប់កាន់កាប់ដោយរដ្ឋបាលសុរិយោដីថ្នាក់ជាតិ និងមួយច្បាប់ទៀត កាន់កាប់ដោយរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ។

ទម្រង់ និងទំហំ នៃសៀវភៅនីមួយៗ ត្រូវបានកំណត់ដូចខាងក្រោម :

- ទំហំក្រដាស A 4
- កម្រាស់ ១០០ សន្លឹក ( = ២០០ទំព័រ )
- មួយទំព័រសម្រាប់ចុះមួយចំណែកឯកជននៃអគារសហកម្មសិទ្ធិ ។

សៀវភៅមួយក្បាលសម្រាប់ចុះចំណែកឯកជនមួយអគារសហកម្មសិទ្ធិ ។ ករណី អគារសហកម្មសិទ្ធិមានចំណែកឯកជនលើសពីពីររយ រដ្ឋបាលសុរិយោដីអាចប្រើសៀវភៅច្រើនក្បាល តាមជាក់ស្តែង ។

ប្រការ ៧ .-

វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវបានផ្តល់ជូនសហកម្មសិទ្ធិករ បន្ទាប់ពីផុតរយៈពេលនៃការបិទផ្សាយទិន្នន័យជាសាធារណៈ ហើយពុំមានការជំទាស់ ឬ ការតវ៉ា ឬ ត្រូវបានបញ្ចប់ការដោះស្រាយវិវាទដោយជោគជ័យ ។

វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជន នៃអគារសហកម្មសិទ្ធិ ត្រូវបានផ្តល់ជូនអ្នកជួលអចិន្ត្រៃយ៍ (ភតិក:) បន្ទាប់ពីផុតរយ:ពេលនៃការបិទផ្សាយទិន្នន័យជាសាធារណ: ហើយពុំមានការជំទាស់ ឬការតវ៉ា ឬបន្ទាប់ពីបានបញ្ចប់ការដោះស្រាយវិវាទដោយជោគជ័យ ។

## ប្រការ ៨ .-

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវធ្វើសេចក្តីណែនាំលំអិត ស្តីពីការបំពេញ ការប្រើប្រាស់ និង ការកាន់កាប់ឯកសារដូចមានចែងក្នុងប្រការ១ ។

## ប្រការ ៩ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

## ប្រការ ១០ .-

ប្រកាសនេះចាប់អនុវត្ត ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

អ៊ឹម ឈុនលឹម

ចម្លងជូន :

ទីស្តីការគណ:រដ្ឋមន្ត្រី

ក្រសួងយុត្តិធម៌

ក្រសួងមហាផ្ទៃ

គ្រប់សាលារាជធានី-ខេត្ត

" ដើម្បីសូមជូនជ្រាប "

អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

គ្រប់មន្ទីរដនសស.រាជធានី-ខេត្ត

" ដើម្បីអនុវត្ត "

- ឯកសារ-កាលប្បវត្តិ